# បញ្ជាំងពន្លឺលើទារុណកម្ម

នៅក្នុងសក្ខីកម្មរបស់លោកជូនសាលាក្ដីខ្មែរក្រហមកាលពីជិតពីរឆ្នាំកន្លងទៅ លោកវ៉ាន់ ណាត ដែលជាវិចិត្រករដ៏ចំណានម្នាក់ បានពិពណ៌នាអំពីព្រឹត្តិការណ៍ដែលបានជំរុញឲ្យគាត់គូសគំនូរមួយផ្ទាំង ដែលបច្ចុប្បន្ននេះកំពុងព្យួរនៅមន្ទីស២១។ រូបភាពនោះបានបង្ហាញបុរសម្នាក់ ដៃចងទៅក្រោយ កំពុងត្រូវគេព្យួរលើបង្គោលឈើមួយដែលសិស្សសាលាធ្លាប់លែងពីមុន។ រូបភាពមួយផ្សេងទៀត បង្ហាញពីបុរសម្នាក់កំពុងត្រូវគេចាប់ជ្រមុចក្បាលចូលក្នុងពាងទឹកដ៏ធំមួយ។ ជនរងគ្រោះរូបនោះ ដែលលោកវ៉ាន់ណាត គ្រាន់តែពិពណ៌នាថាជា "វិចិត្រករមួយរូប" នោះ បានជួបវាសនាដូចជនរងគ្រោះ រាប់ពាន់នាក់ផ្សេងទៀតបន្ទាប់ពីសារភាពក្រោមទារុណកម្មរួចមក។ រូបភាពរបស់លោកស្ថិតនៅជា ការរំលឹកជានិរន្តនៃភាពអនាមិករបស់ជនរងគ្រោះនៃទារុណកម្មជាច្រើននៅទូទាំងពិភពលោក ដែលការឈឺចាប់របស់ពួកគេជាច្រើនមិនទាន់ត្រូវគេដឹង និងមិនទាន់ត្រូវគេចងក្រងជាឯកសារ នៅឡើយ។



ថ្ងៃនេះជាទិវាអន្តរជាតិគាំទ្រជនរងគ្រោះនៃទារុណកម្ម ដែលជាទិវាដើម្បីចងចាំដល់ជនរងគ្រោះ និងសង្កត់ធ្ងន់លើការហាមឃាត់យ៉ាងច្បាស់លាស់ និងជាដាច់ខាតចំពោះទារុណកម្ម និងគ្រប់ទម្រង់នៃការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។ វាក៏ជាខួបលើកទី២៥នៃអនុសញ្ញាអ.ស.បប្រឆាំងទារុណកម្ម ដែលចូលជាធរមានកាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៨៧ផងដែរ។

វាមានតំលៃធំធេងណាស់ដែលយើងត្រូវចងចាំថា ទារុណកម្មត្រូវបានផ្តល់និយមន័យនៅក្រោមច្បាប់អន្តរជាតិថាជា ការបង្ករដោយចេតនានូវការឈឺចាប់ធ្ងន់ធ្ងរខាងផ្លូវកាយ ឬផ្លូវចិត្ត ដោយឬក្នុងនាមអាជ្ញាធរ លើបុគ្គលណាម្នាក់ដើម្បីទទួលបានព័ត៌មាន ឬដាក់ទណ្ឌកម្ម បំភិតបំភៃ ឬដើម្បីបង្ខំបុគ្គលនោះ ឬបុគ្គលនានាផ្សេងទៀត។

ការហាមឃាត់ប្រឆាំងនឹងទារុណកម្មនៅតែជាសរសរស្តំជាមូលដ្ឋាន នៅក្នុងការការពារ និងលើកស្ទួយសិទ្ធិមនុស្ស។ ការរិតត្បិតនានាអាចត្រូវបានដាក់លើការប្រើប្រាស់សិទ្ធិមនុស្សមួយចំនួន ប៉ុន្តែមិនអាចដាក់លើការការពារពីទារុណកម្មបាននោះទេ។ ដូចគ្នានឹងទាសករ និងអំពើប្រល័យពូជសាសន៍ដែរ ការហាមឃាត់មានលក្ខណៈដាច់ខាត។ បទបញ្ជាពីថ្នាក់លើពុំមែនជាការដោះសារក្នុងការប្រព្រឹត្តទារុណកម្មនោះទេ។ ការបញ្ជូនបុគ្គលណាម្នាក់ទៅកាន់ប្រទេសមួយផ្សេងទៀត ដែលមានហានិភ័យនៃការធ្វើទារុណកម្ម មិនអាចទទួលយកបាននោះទេ។ ទាំងអស់នេះឆ្លុះបញ្ចាំងពីការស្អប់ខ្ពើមជាខ្លាំងនៃសហគមន៍អន្តរជាតិលើបទទារុណកម្ម។

គ្រប់ប្រទេសទាំងអស់មិនត្រូវអធ្យាស្រ័យចំពោះទារុណកម្មជាដាច់ខាត។ តាមចរិតលក្ខណៈរបស់វា ទារុណកម្មធ្វើឡើងដោយលាក់កំបាំង ពីក្រសែភ្នែកសាធារណជន។ វាអាចកើតឡើងក្នុងពន្ធនាគារ និងស្ថានីយ៍នគរបាល ប៉ុន្តែក៏អាចនៅទីកន្លែងផ្សេងៗទៀតដូចជា មណ្ឌលឃុំខ្លួនអន្តោប្រវេសន៍ មន្ទីរពេទ្យសុខភាពផ្លូវចិត្ត មណ្ឌលសង្គមកិច្ច ឬមណ្ឌលផ្តាច់គ្រឿងញៀន។ មនុស្សដែលត្រូវឃុំខ្លួនក្នុងកន្លែងអស់ទាំងនេះនៅទូទាំងពិភពលោក ប្រឈមនឹងហានិភ័យនៃការរំលោភសិទ្ធិមនុស្ស ប៉ុន្តែទារុណកម្មនិងការដកហូតសេរីភាពគឺជាការប្រឈមដ៏ធ្ងន់ធ្ងរបំផុត។ ដោយហេតុនេះហើយ គេត្រូវការបង្កើតឲ្យមានការធានាការពារជាក់លាក់មួយចំនួន។ មន្ត្រីអនុវត្តន៍ច្បាប់ត្រូវតែទទួលបានការអប់រំអំពីការហាមឃាត់ទារុណកម្ម និងរបៀបទៅស្គាល់ នៅពេលវាកើតឡើង។ ការប្តឹងពីទារុណកម្ម ឬសូម្បីតែការសង្ស័យសមហេតុផលមួយ ត្រូវតែធ្វើការស៊ើបសង្កេតភ្លាមៗ និងដោយអនាគតិ ព្រមទាំងត្រូវមានប្រព័ន្ធមួយដើម្បីការពារអ្នកប្តឹងៗពីការបំភិតបំភ័យ និងការសងសឹក។ ហើយនៅកន្លែងណាដែលរកឃើញមានទារុណកម្ម អស់អ្នកដែលទទួលខុសត្រូវ ត្រូវតែប្រឈមមុខនឹងបណ្តឹងអាជ្ញា និងផ្តន្ទាទោសក្នុងពេលវេលាដ៏សមស្របមួយ ហើយជនរងគ្រោះត្រូវទទួលបានសំណងជម្ងឺចិត្ត។

យោងតាមប្រវត្តិសាស្ត្រ ការហាមឃាត់ទារុណកម្មមានអត្ថន័យយ៉ាងជ្រាលជ្រៅនៅក្នុងប្រទេសកម្ពុជា។ ប្រជាជនជាច្រើន ប្រសិនបើមិនមែនភាគច្រើន សុទ្ធតែមានទំនាក់ទំនងនឹងជនរងគ្រោះណាម្នាក់ ដែលទទួលរងទារុណកម្មនៅកំឡុងសម័យខ្មែរក្រហម ឬខ្លួនពួកគេផ្ទាល់ជាជនរងគ្រោះតែម្តង។ ប្រហែលជាច្រើនជាង សង្គមណាៗទាំងអស់ ប្រជាជនកម្ពុជាស្គាល់យ៉ាងច្បាស់

អំពីផលអន្តរាយដែលអំពើទារុណកម្មបង្ករដល់ ជនរងគ្រោះ គ្រួសាររបស់ពួកគេ និងសហគមន៍ទាំងមូល។

វាគឺជាដំណឹងជាទីស្វាគមន៍ដែលកម្ពុជាបានខិតខំប្រឹងប្រែងដោះស្រាយជាមួយទារុណកម្ម ដែលបានប្រព្រឹត្តក្នុងអតីតកាល និងដោះស្រាយហានិភ័យនៃទារុណកម្មក្នុងប្រទេសនេះ នាពេលបច្ចុប្បន្ន។ ការជំនុំជម្រះ និងការប្រកាសទោសឌុចដោយECCC ចារិកទុកជាលើកដំបូងនូវការផន្ទាទោសមន្ត្រីសាធារណៈ សម្រាប់អំពើទារុណកម្ម យ៉ាងហោចណាស់ចាប់ពីសម័យខ្មែរក្រហមមក។ ការសម្រេចសេចក្តីជាប្រវត្តិសាស្ត្រនេះ គឺជាទឡ្ហីករណ៍ចំពោះការប្តេជ្ញារបស់កម្ពុជា ក្នុងការនិយាយ "មិនមានជាថ្មី" នៃអំពើឃោឃៅជាទ្រង់ទ្រាយធំ និងការប្រើប្រាស់កំលាំងបង្ខិតបង្ខំរបស់មន្ត្រីសាធារណៈ ដើម្បីទាញយកព័ត៌មាន ឬការសារភាព។

ស្របពេលនេះដែរ កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសមួយចំនួនតូចនៅអាស៊ី ដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញាអ.ស.បប្រឆាំងទារុណកម្ម ក៏ដូចជាពិធីសារបន្ថែមរបស់វា។ ការផ្តល់សច្ចាប័នដល់ពិធីសារបន្ថែមមានសារសំខាន់ជាសារវ័ន្តៈ រដ្ឋាភិបាលប្តេជ្ញាទទួលទស្សនកិច្ចពីសំណាក់អនុគណៈកម្មាធិការអន្តរជាតិស្តីពីការបង្ការទារុណកម្ម ក៏ដូចជាបង្កើតយន្តការបង្ការថ្នាក់ជាតិ ដើម្បីធ្វើរដ្ឋបាលកិច្ចទៅគ្រប់កន្លែងឃុំខ្លួនទាំងអស់ ដើម្បីកាត់បន្ថយហានិភ័យនៃទារុណកម្ម។ ប្រទេសកម្ពុជាបានស្វាគមន៍គណៈកម្មាធិការនេះនៅឆ្នាំ២០០៩ ដោយអនុញ្ញាតឲ្យអនុគណៈកម្មាធិការនេះធ្វើទស្សនកិច្ចទៅគ្រប់កន្លែងឃុំខ្លួនទាំងអស់ដោយគ្មានការរិតត្បិត។ កិច្ចខិតខំប្រឹងប្រែងនានាក្នុងការបង្កើតយន្តការបង្ការឯករាជ្យមួយនៅកម្ពុជា កំពុងដំណើរការទៅមុខយ៉ាងល្អប្រសើរ។ ឯករាជភាព ជំនាញ និងធនធានដែលត្រូវផ្តល់ឲ្យយន្តការនេះ គឺជាគន្លឹះចំពោះការជោគជ័យរបស់វា។

ការអប់រំជនជាប់ឃុំគឺជាវិធីមួយនៃការកាត់មន្ថយហានិភ័យនៃទារុណកម្ម។ ជនជាប់ឃុំនានាដែលយល់ដឹងពីសិទ្ធិរបស់ពួកគេ មិនងាយនឹងត្រូវបានប្រព្រឹត្តមកលើខ្លួនដោយមិនគប្បី។ នេះគឺជាមូលហេតុដែលក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និងឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស បានបង្កើតប័ណ្ណសិទ្ធិឃាត់ខ្លួនមួយ ដែលពិពណ៌នាក្នុងភាសាសាមញ្ញនូវសិទ្ធិនានារបស់បុគ្គលដែលត្រូវបានចាប់ខ្លួន និងឃាត់ខ្លួននៅស្ថានីយ៍នគរបាល។

យើងសង្ឃឹមថាប័ណ្ណនេះនឹងត្រូវបានផ្តល់ជូនគ្រប់ស្ថានីយ៍នគរបាលទាំងអស់នៅទូទាំងប្រទេសក្នុងពេលឆាប់ៗនេះ។

ទារុណកម្មពុំមានចំណែកនៅក្នុងសង្គមណាមួយនោះទេ។ ពួកយើងភាគច្រើនសុទ្ធតែឯកភាពលើចំនុចរួចស្រេចទៅហើយ។ យ៉ាងណាមិញ ទារុណកម្មជានិច្ចកាលនៅតែបន្តកើតឡើងនៅក្នុងប្រទេសទាំងអស់ ទាំងប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍។ ការអប់រំនៃមន្ត្រី មេធាវី និងសាធារណជនទូទៅ ការចុះត្រួតពិនិត្យដោយឯករាជ្យនៅកន្លែងឃុំខ្លួនដោយមិនប្រកាសឲ្យដឹង ការស៊ើបអង្កេតលើបណ្តឹងដោយឯករាជ្យនិងហ្មត់ចត់។ ការផ្តន្ទាទោស និងប្រកាសទោសប្រឆាំងជនប្រព្រឹត្តទារុណកម្មៈ យើងដឹងថាសកម្មភាពទាំងនេះកាត់បន្ថយហានិភ័យនៃបទល្មើសដ៏យង់ឃ្នងនេះ។ ការប្រឈមនាពេលនេះគឺការដាក់ការជឿជាក់របស់យើង ទៅក្នុងសកម្មភាព និងបន្តការប្រុងប្រយ័ត្ន។

*លោក **ជេមស៍ ហ៊ីណិន** គឺជាតំណាងរង និងជាមន្ត្រីទទួលបន្ទុកការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា។*